ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# គម្រោងអាជីវកម្ម
# ដំណាំទៀបស្រុក



រៀបចំដោយ
នាយកដ្ឋានគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ
ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB)

ខែមិថុនា ឆ្នាំ២០២៦

012 678 855
070 463 219
# 168, Street 7, Prek Leap Village, Sangkat Prek Leap, Khan Chroy Changva, Phnom Penh

**១-សេចក្តីផ្តើម** ........................................ ១
**២-ការអនុវត្តការដាំដុះ** ........................................ ១
២.១- ការជ្រើសទីតាំង និងដី ........................................ ១
២.២- អាកាសធាតុ សីតុណ្ហភាព និងកម្រិតសំណើម ........................................ ១
២.៣- ការជ្រើសរើសពូជ ........................................ ១
២.៣.១- កូនបណ្តុះគ្រាប់........................................ ២
២.៣.២- កូនតត្រួយ ........................................ ២
២.៣.៣- កូនផ្សាំមែក........................................ ២
២.៤- ពេលវេលាដាំដុះ ........................................ ២
២.៤.១- ការរៀបចំរណ្តៅ........................................ ៣
២.៤.២- ការដាក់ដាំកូនទៀប........................................ ៣
**៣-ការថែទាំ** ........................................ ៣
៣.១- ការស្រោចទឹក ........................................ ៣
៣.២- ការដាក់ជីដំណាំទៀប........................................ ៣
៣.៣- ការគ្រប់គ្រងស្មៅ........................................ ៤
៣.៤- ការតាក់តែងមែក........................................ ៥
៣.៥- ការបូតជម្រុះស្លឹក........................................ ៥
៣.៦- ការចេញផ្កា ផ្លែ ........................................ ៥
៣.៧- ការគ្រប់គ្រងសត្វល្អិត........................................ ៦
៣.៧.១- ចៃស (Mealybug)........................................ ៦
៣.៧.២- ចៃក្រមួន (Scales) ........................................ ៦
៣.៧.៣- ដង្កូវចោះផ្លែ (Fruit Borer/ Fruit boring caterpillar)........................................ ៦
៣.៧.៤- រុយចោះផ្លែ (Fruit Fly) ........................................ ៧
៣.៨.- ការគ្រប់គ្រងជំងឺ ........................................ ៨
៣.៨.១- ជំងឺអង់ត្រាក់ណូស (Anthracnose) ........................................ ៨
៣.៨.២- ជំងឺអុចស្លឹក (Leave Spot) ........................................ ៨
៣.៨.៣- ជំងឺរលួយឌីផ្លូឌីយា (Diplodia) ........................................ ៨
៣.៨.៤- ជំងឺដំបៅពណ៌ខ្មៅ(Black Canker)........................................ ៩
**៤-ការប្រមូលផល** ........................................ ១០

៤.១- លក្ខណៈផ្លែចាស់ ........................................................ ១០
៤.២- ការដាក់បន្ទុំ ........................................................ ១០
៤.៣- ទិន្នផលទៀបស្វិតតាមអាយុកាល ........................................................ ១០
**៥-ការវិភាគសេដ្ឋកិច្ចលើការដាំដំណាំទៀបស្វិតលើផ្ទៃដី១ហិកតា ........................................ ១១**
៥.១- តារាងវិភាគសេដ្ឋកិច្ចលើការដាំដុះដំណាំទៀបស្វិត ........................................ ១១
៥.២- តារាង ចំណេញ- ខាត ........................................................ ១៥
៥.៣- ថ្លៃដើមផលិតកម្ម/១គីឡូក្រាម ........................................................ ១៥
**៦-បញ្ហាប្រឈម ........................................................ ១៦**
**៧-សេចក្តីសន្និដ្ឋាន ........................................................ ១៧**
**៨-ប្រភពសិក្សា-ឯកសារ ........................................................ ១៧**

# ដំណាំទៀបស្វិត

## ១-សេចក្តីផ្តើម

ទៀបស្វិតខ្មែរជាដំណាំឈើហូបផ្លែមួយប្រភេទដែលអ្នកស្រុកតែងនិយមដាំនៅលើដីលំនៅដ្ឋានជាយូរយារមកហើយសម្រាប់បរិភោគជាលក្ខណៈគ្រួសារ តែក៏អាចឱ្យកសិកររកប្រាក់ចំណូលដើម្បីជំនួយដល់ជីវភាពគ្រួសារបានប្រសើរផងដែរ ដោយសារទីផ្សារក្នុងស្រុកល្អ។ ទៀបជាប្រភេទដំណាំឆាប់ឱ្យផលអាយុវែង សំណុំដើមតូច ជាដំណាំងាយស្រួលក្នុងការថែទាំ ផ្តល់ទិន្នផលជាមធ្យមពី ១០-១៤ តោនក្នុង១ហិកតាក្នុង១ឆ្នាំ ឬលើសពីនេះអាស្រ័យលើការថែទាំ និងអាចបន្តប្រមូលផលរហូតដល់អាយុ២០ឆ្នាំ។

## ២-ការអនុវត្តការដាំដុះ

### ២.១-ការជ្រើសទីតាំង និងដី

ដំណាំទៀបអាចដុះលូតលាស់បានលើដីស្ទើរគ្រប់ប្រភេទដែលមានទម្រង់រចនាសម្ព័ន្ធល្អ មិនហាប់ណែន ស្រស់ទឹកល្អ និងមិនលិចទឹក។ ទឹកច្រើនពេកនាំឱ្យដើមទៀបអាចមានបញ្ហារលាក ឬរលួយឫសនៅពេលដីមានសភាពឥដ្ឋខ្លាំង និងថ្មនៅជម្រៅតិចជាង១ម៉ែត្រ។ ដីចម្ការដែលធ្លាប់ដាំដុះម្ទេស គ្រប់ដំឡូងបារាំង ប៉េងប៉ោះ និងខ្ទឹម អាចបង្ករជាជំងឺដល់ដំណាំទៀប ព្រោះដំណាំទាំងនេះតែងបន្សល់នូវជំងឺរលួយឫសនៅដីចម្ការ។ កសិកគួរយកដីទៅវិភាគរកសារធាតុចិញ្ចឹម និងវាស់ pH ដី ឱ្យបានត្រឹមត្រូវ ដើម្បីងាយស្រួលក្នុងការកំណត់ប្រភេទដី និងកម្រិតជីដែលត្រូវដាក់ឱ្យស្របតាមតម្រូវការនៃដំណាំទៀប។ កម្រិត pH ដីនៅចន្លោះ ៦-៧.៥ គឺអាចឱ្យដំណាំទៀបលូតលាស់បានល្អ ក្នុងករណី pH ទាប កសិករអាចបង្កើនកម្រិត pH ដីដោយប្រើកំបោរកសិកម្ម ($CaCO_3$) និងបើដី pH ខ្ពស់ពេក កសិករអាចបញ្ចុះ pH ដីដោយប្រើស្ពាន់ធ័រ (Sulphur)។

### ២.២-អាកាសធាតុ សីតុណ្ហភាព និងកម្រិតសំណើម

ដំណាំទៀបត្រូវការអាកាសធាតុ ក្តៅ-សើម ដែលមានសីតុណ្ហភាពនៅចន្លោះ ២៥-២៨អង្សារ និងសំណើមបរិយាកាស ៧០-៨០% នៅវគ្គចេញផ្កា-ផ្លែ ដែលជាលក្ខខណ្ឌសមស្របដល់ការលូតលាស់ កាន់ក្តិប និងមានទម្រង់ផ្លែល្អ មួយវិញទៀត ទៀបអាចធន់នឹងសីតុណ្ហភាពត្រជាក់ដល់ ១៣ អង្សារសេ និងទាមទារការស្រោចស្រពនៅរដូវប្រាំង។

### ២.៣- ការជ្រើសរើសពូជ

កសិករត្រូវជ្រើសពូជដែលមានលក្ខណៈល្អពីដើមមេដូចជា មានទម្រង់ដើម ស្លឹក ផ្លែល្អ ចំនួនផ្លែច្រើន រសជាតិផ្អែមឆ្ងាញ់ និងមានតម្រូវការទីផ្សារ។ ពូជសំខាន់ៗដែលកសិករយើងកំពុងដាំមាន ២ គឺ÷ ពូជទៀបស្វិត និងទៀបបាយ។ ទៀបស្វិតមានជាតិផ្អែម (ស្ករខ្ពស់) ងាយស្រួយបកសំបកពេលទុំ ហើយជាពូជដែលកសិករនិយមដាំច្រើនជាងគេ។ ចំណែកទៀបបាយមានរសជាតិផ្អែមល្មម សំបករាងស្អិតជាប់សាច់បន្តិច សាច់ជ្រាយពេលទុំ។ កសិករអាចមានជម្រើសក្នុងការដាំដោយគ្រាប់ ដោយតត្រួយ និងមែក

ផ្សាំ។ កូនដែលបណ្ដុះដោយគ្រាប់ អាចយកទៅដាំបានគួរមានកម្ពស់ពី ៤០ ទៅ ៦០សង់ទីម៉ែត្រ។ ការផ្សាំ និងតត្រួយឆាប់ចេញផ្កា-ផ្លែមុន បើធៀបនឹងកូនពូជបណ្ដុះដោយគ្រាប់។

**២.៣.១-ការបណ្ដុះគ្រាប់÷** ជ្រើសរើសគ្រាប់ពីផ្លែដែលមានទំហំធំល្អ រាងស្មើសាច់ ទំហំគ្រាប់ធំប្រហាក់ប្រហែលគ្នា។ កសិករយកគ្រាប់ពីផ្លែទុំល្អ មកលាងទឹក រួចហាលនឹងកម្ដៅថ្ងៃពី ២-៣ម៉ោង បន្ទាប់មកត្រាំទឹក១យប់ ទើបដាក់ពង្រាយគ្រាប់លើដីក្នុងកេះស្មោ និងបាញ់ទឹកតិចៗ ដោយដាក់គ្របទុករយៈពេល១សប្ដាហ៍ដើម្បីជំរុញដំណុះលឿន។ ហើយនៅពេលកូនទៀបដុះពន្លក កសិករអាចយកទៅដាំផ្សាំក្នុងត្រេ ឬថង់ផ្សាំបាន។ នៅពេលកូនមានអាយុពី ៣-៤ ខែទើបអាចយកទៅដាំនៅចម្ការបាន។

**២.៣.២-កូនតត្រួយ÷** កសិករត្រូវយកកូនដែលបានបណ្ដុះអាយុពី ២-៣ខែ ទៅភ្ជាប់ជាមួយត្រួយដើមពូជដែលមានសុខភាពល្អ ផ្លែច្រើន ផ្លែធំល្អ រសជាតិឆ្ងាញ់។ ការដាំដំណាំទៀបពីការតត្រួយអាចរក្សាលក្ខណៈដើមរបស់មេពូជបានល្អដោយសារគ្មានការឆ្លងលំអងពីពូជដទៃតាមរយៈខ្យល់ និងសត្វល្អិតឡើយ។

**២.៣.៣-កូនផ្សាំមែក÷** កសិករត្រូវជ្រើសដើមដែលមានសុខភាពល្អ មែកត្រង់ស្រឡូនល្អដែលដុះចេញពីដើមមេផ្ទាល់ មានមុខកាត់ទំហំចាប់ពី ១-១,៥ស.ម ឡើងទៅ។ ចំណុចផ្សាំត្រូវទុកគម្លាតពីដើមមេប្រវែង ១៥-២០ ស.ម ដើម្បីងាយកាត់ពេលដុះឫស។ របៀបផ្សាំ គឺត្រូវសកសំបកជុំវិញមែកផ្សាំប្រវែង ៣-៤ ស.ម រួចកោសរំអិលឱ្យអស់ ហើយទុកឱ្យស្ងួតរយៈពេល ២០-៣០ នាទី ទើបយកស្រកីដូង ឬដីមមោក រុំព័ទ្ធជុំវិញចងឱ្យណែន ស្រោចទឹកឱ្យជោគ រុំប្លាស្ទិកពីក្រៅ ត្រួតពិនិត្យ និងគ្រប់គ្រងសំណើមជាប្រចាំ។ បន្ទាប់ពីផ្សាំបានរយៈពេល ២០- ៣០ថ្ងៃ ឫសនឹងដុះចេញពេញស្រកីដូង កសិករអាចកាត់យកទៅដាក់ផ្សាំក្នុងថង់ទុករយៈពេល ២០-៣០ថ្ងៃ ទើបអាចយកទៅដាំបន្តក្នុងចម្ការបាន។



បណ្ដុះដោយគ្រាប់



វិធីតត្រួយ



ពូជទៀបស្វិតដោយផ្សាំមែក

## ២.៤-ពេលវេលាដាំដុះ

ពេលវេលាដាំដុះល្អបំផុតគឺនៅដើមរដូវវស្សាចន្លោះខែឧសភា-សីហា នៅដើមរដូវភ្លៀងជាពេលវេលាដែលមានសីតុណ្ហភាព និងសំណើមបរិយាកាសអំណោយផលសម្រាប់ការលូតលាស់។

**២.៤.១-ការរៀបចំរណ្តៅ ÷** ការជីករណ្តៅទំហំ ៤០ ស.ម x ៤០ ស.ម x ៦០ ស.ម ជម្រៅ ដោយទុកគម្លាតដើម ៤ម៉ែត្រ និងគម្លាតជួរ ៥ម៉ែត្រ កសិករអាចដាំដើមទៀបបាន៥០០ដើម/ហិកតា ក្នុងរណ្តៅនីមួយៗត្រូវដាក់ជីកំប៉ុស និងជីគីមីទ្រាប់បាត ដោយលាយច្របល់ជាមួយដីស្រទាប់លើនៃរណ្តៅ។ សម្រាប់ផ្ទៃចម្ការតូចៗ កសិករអាចជ្រើសគម្លាតជួរ និងដើម ៣ ម៉ x ៣ ម៉(១ ០៨៩ ដើម/ហិកតា) និង ៣ ម៉ x ៤ ម៉(៨២៥ ដើម/ហិកតា)។

**២.៤.២-ការដាក់ដាំកូនទៀប÷**ត្រូវយកកូនពូជទៀបទៅពង្រាយតាមរណ្តៅដែលបានរៀបចំរួច។ ត្រូវកាត់ឫសដែលដុះព័ទ្ធចេញ និងហែកថង់ផ្សាំដោយប្រុងប្រយ័ត្នដើម្បីជៀសវាងការបែកដីនាំឱ្យអន់ឬងាប់នៅពេលក្រោយដាំរួច។ ត្រូវកប់កូនទៀបដោយលៃយ៉ាងណាឱ្យដីលុបគល់ស្មើនឹងមាត់រណ្តៅ ហើយសង្កត់ដីឱ្យណែនជុំវិញគល់ និងស្រោចទឹកមួយជោគ។ ក្រោយដាំរួច ត្រូវដោតបង្គោលចងខ្សែទប់កុំឱ្យរង្គើរដើម្បីឆាប់ចេញឫសថ្មី។



ការដាក់ដាំកូនទៀប

## ៣-ការថែទាំ

### ៣.១- ការស្រោចទឹក

ការស្រោចទឹកទៀងទាត់ជាពិសេសនៅរដូវប្រាំង ជួយឱ្យដំណាំទៀបធន់នឹងសត្វល្អិត ជំងឺ និងបង្កើនទិន្នផល។ បរិមាណស្រោចស្រពប្រែប្រួលតាមអាយុកាល កម្រិតរំហួតប្រចាំថ្ងៃ និងប្រភេទដី (ខ្សាច់ ល្បាយ និងឥដ្ឋ)។

| អាយុកាល | បរិមាណទឹកសម្រាប់ស្រោចស្រព |
|---|---|
| ដើមទៀបអាយុក្រោម០-១ឆ្នាំ | ស្រោចម្តង ៥លីត្រ/ ដើម និង៣ដងក្នុង១សប្តាហ៍ |
| ដើមទៀបអាយុ ២ ឆ្នាំ | ស្រោចម្តង ៧លីត្រ/ ដើម និង៣ដងក្នុង១សប្តាហ៍ |
| ដើមទៀបអាយុ ៣ ឆ្នាំ | ស្រោចម្តង ៩លីត្រ/ ដើម និង៣ដងក្នុង១សប្តាហ៍ |
| ដើមទៀបអាយុ ៤ ឆ្នាំ | ស្រោចម្តង ១២លីត្រ/ ដើម និង៣ដងក្នុង១សប្តាហ៍ |
| ដើមទៀបអាយុ៥ឆ្នាំឡើង | ស្រោចម្តង ១៥ -២០ លីត្រ/ ដើម និង៣ដងក្នុង១សប្តាហ៍ |

សម្គាល់÷ ការស្រោចស្រពអាចប្រែប្រួលតាមស្ថានភាពជាក់ស្តែងនៃសំណើមដីក្នុងចម្ការទៀប។

### ៣.២- ការដាក់ជីដំណាំទៀប

ដើម្បីដាក់ជីឱ្យបានត្រឹមត្រូវ បង្ការការដាក់ជីលើស ឬខ្វះ កសិករគួរយកសំណាកដីទៅវិភាគនៅមន្ទីរពិសោធន៍។ ការបន្ថែម ជី NPK (២០-២០-១៥) តាមដំណាក់កាលដូចជា ទ្រាប់បាត លូតលាស់ និងចេញផ្កា-ផ្លែ។ មុនដាក់ជីត្រូវបន្ថយស្រោចទឹកដើម្បីបង្កើនការស្រូបយកជីបានល្អ និងមានប្រសិទ្ធភាព។ ការណែនាំការប្រើប្រាស់ជីជាទូទៅសម្រាប់ដំណាំទៀបដូចខាងក្រោម÷

| អាយុកាល | ប្រភេទជី | កម្រិតប្រើ ដើម/ឆ្នាំ | ចំនួនដង/ឆ្នាំ | សំគាល់ |
|---|---|---|---|---|
| ទ្រាប់បាត | កំប៉ុស | ៥ គ.ក្រ | | ដាក់កប់ក្នុងរណ្តៅ |
| | គីមី (២០-២០-១៥) | 0.១ គ. ក្រ | | ដាក់កប់ក្នុងរណ្តៅ |
| | កំបោរកសិកម្ម | 0.១ គ. ក្រ | ១ | បាចកប់ក្នុងរណ្តៅឬជុំវិញ |
| អាយុ១ឆ្នាំ | កំប៉ុស | ៥ គ.ក្រ | | ដាក់បំប៉នចុងរដូវភ្លៀង |
| | គីមី (២០-២០-១៥) | ០.២គ.ក្រ | ១ | ដាក់បំប៉ន ២-៣ខែក្រោយដាំ កញ្ញា-តុលា |
| អាយុ២ឆ្នាំ | កំប៉ុស | ១០ គ.ក្រ | ១ | ឧសភា-មិថុនា |
| | គីមី (២០-២០-១៥) | ០.៤ គ.ក្រ | ២ | ឧសភា-មិថុនា និងកញ្ញា-តុលាក្នុងរដូវភ្លៀង |
| | កំបោរកសិកម្ម | ០.២គ.ក្រ | ១ | បាញ់ជុំវិញគល់ |
| អាយុ៣ឆ្នាំ | កំប៉ុស | ១៥គ.ក្រ | ១ | ឧសភា-មិថុនានៅដើមរដូវភ្លៀង |

| | | | | |
|---|---|---|---|---|
| | គីមី (២០-២០-១៥) | ០.៤ គ.ក្រ | ២ | ឧសភា-មិថុនា) និង (កញ្ញា-តុលា) ដើមនិងចុងរដូវភ្លៀង |
| | កំបោរកសិកម្ម | ០.២គ.ក្រ | ១ | បាញ់ជុំវិញគល់ |
| ៤-៦ឆ្នាំឡើងទៅ | កំប៉ុស | ២០-៤០ គ.ក្រ | ១ | ឧសភា-មិថុនា នៅដើមរដូវភ្លៀង |
| | គីមី (២០-២០-១៥) | ១-១.៤គ.ក្រ | ២ | ឧសភា-មិថុនា និងកញ្ញា-តុលា នៅដើមនិងចុងរដូវភ្លៀង |
| | កំបោរកសិកម្ម | ០.២គ.ក្រ | ១ | បាញ់ជុំវិញគល់ |

ការប្រើប្រាស់ជីឱ្យមានតុល្យភាពនឹងធ្វើឱ្យដំណាំទៀបលូតលាស់ល្អ ធន់នឹងសត្វល្អិតនិងជំងឺ ផលិតផ្កា និងផ្លែបានល្អ មិនក្ងៀប ឬជ្រុះ។ បរិមាណជីដែលត្រូវដាក់អាចនឹងប្រែប្រួលតាមស្ថានភាពដី និងតម្រូវការជាក់ស្តែងរបស់ដំណាំទៀប។

### ៣.៣- ការគ្រប់គ្រងស្មៅ

ស្មៅដែលប្រជែងនឹងដំណាំទៀបមានច្រើនប្រភេទ។ ការគ្រប់គ្រងស្មៅក្នុងដំណាំទៀបគឺមានសារៈសំខាន់ណាស់ ដើម្បីធានាបាននូវការកើនទិន្នផលខ្ពស់ និងបន្ថយការប្រជែងស្រូបសារធាតុចិញ្ចឹម។ វិធីសាស្ត្ររួមមាន÷ ការដកស្មៅដោយដៃ កាត់ដោយម៉ាស៊ីន ត្រាក់ទ័រកាត់(ចម្ការធំ) គ្របប្លាស្ទិក គ្របចំបើង គ្របកម្ទេកកម្ទីរុក្ខជាតិស្ងួតជុំវិញគល់ និងចុងក្រោយប្រើប្រាស់ថ្នាំសម្លាប់ស្មៅបើទំហំចម្ការធំ តែមិនត្រូវបាញ់ប៉ះស្លឹក និងផ្លែឡើយ។ ការគ្រប់គ្រងស្មៅត្រូវធ្វើរហូតដល់ដំណាំទៀបលូតលាស់ធំពេញ ទើបស្មៅទាំងនោះលែងប្រជែងឈ្នះដំណាំទៀប។

### ៣.៤- ការតាក់តែងមែក

នៅពេលកាត់តាក់តែងមែក ត្រូវទុកមែកធំៗដែលដុះចេញពីដើមមេ កម្ពស់ពីដីប្រហែល ៥០-៦០ សង់ទីម៉ែត្រ។ គួរទុកតែ ៣ ទៅ ៤ មែក ដែលដុះទៅទិសផ្សេងគ្នា (រាងដូចអក្សរ Y ឬរាងឆត្រ)។ ប្រសិនបើមែកណាមួយដុះខ្ពស់ពេក ត្រូវកាត់ត្រឹមចុង ដើម្បីបង្ខំឱ្យវាបែកមែកខ្នែងទៅចំហៀងវិញ មែកខ្នែង (Secondary branches) គឺជាកន្លែងដែលផ្តល់ផ្កា។ សម្រាប់ការកាត់តែងក្រោយប្រមូលផល ត្រូវកាត់តម្រឹមមែកខ្នែងនីមួយៗឱ្យនៅសល់ប្រវែងប្រហែល ២០ ទៅ ៣០ សង់ទីម៉ែត្រ ពីគល់មែកខ្នែងមក។ មែកដែលអាចកាត់ចេញបន្ថែម ដើម្បីទទួលបានពន្លឺ និងខ្យល់គ្រប់គ្រាន់ដូចជា÷

១)មែកដែលដុះចាក់ចុះក្រោមមែកទាំងនេះមិនសូវទទួលបានពន្លឺថ្ងៃ

២)មែកដែលដុះប្រជ្រៀតគ្នា និងមែកពីរដុះខ្វែងគ្នា ត្រូវកាត់ចោលមួយ

### ៣.៥- ការបូតជម្រុះស្លឹក

នៅពេលទៀបមានអាយុ ២-៥ ឆ្នាំ កសិករអាចជម្រុះស្លឹកស្មើរតែ ៨០% នៃដើម (Defoliation) ដើម្បីឱ្យវាសម្រាក និងត្រៀមចេញផ្កាស្រុះគ្នា។ សម្រាប់ដើមអាយុលើសពី៥ឆ្នាំ មិនចាំបាច់បេះស្លឹកអស់

ពេកទេ ទុកខ្លះដើម្បីជួយផលិតអាហារចិញ្ចឹមដើម។ ក្រោយជម្រុះស្លឹករួចគប្បីបាញ់ថ្នាំលាងដើម (សំខាន់បំផុត) ដោយប្រើប្រាស់ថ្នាំ Copper Hydroxide ឬ Copper Oxychloride លាយជាមួយថ្នាំកម្ចាត់ចៃម្សៅឱ្យជោគទាំងតួដើម ទាំងមែក និងដីជុំវិញគល់ បន្ទាប់មកត្រូវដាក់ជីបំប៉នជីលាមកសត្វផ្ទាប់ ឬជីកំប៉ុស ២០-៤០ គីឡូក្រាម ក្នុងមួយដើម និងជីគីមីលេខ ១៥-១៥-១៥ ចំនួន ០,៥-១ គីឡូក្រាម អាស្រ័យលើទំហំដើម។ ការបន្ថែមជីម៉ាញ៉េស្យូម និងកាល់ស្យូម បានជួយឱ្យស្លឹកថ្មីលូតលាស់មានពណ៌បៃតងចាស់ និងស្លឹកក្រាស់។ ក្រោយការជម្រុះស្លឹកត្រូវផ្អាកស្រោចទឹក ២-៣ ថ្ងៃសិន ទើបចាប់ផ្ដើមស្រោចទឹកឱ្យជោគឡើងវិញ ដើម្បីជំរុញឱ្យត្រួយលាស់ស្រុះគ្នា។ បញ្ជាក់÷ ត្រូវធ្វើក្រោយប្រមូលផលបានពី ១៥-៣០ថ្ងៃ។

### ៣.៦-ការចេញផ្កា ផ្លែ

ដំណាំទៀបអាចចាប់ផ្ដើមចេញផ្កានៅក្នុងអំឡុងខែមេសា-សីហា និងអាចប្រែប្រួលតាមលក្ខខណ្ឌដីអាកាសធាតុ និងការថែទាំ។ ផ្កាទាំងនោះនឹងលូតលាស់ទៅជាផ្លែអាចប្រមូលផលចាប់ផ្ដើមនៅក្នុងខែកក្កដា-វិច្ឆិកា។ ផ្លែទៀបប្រមូលផលពី ៣ ទៅ ៤ ដង បណ្ដាក់គ្នាក្នុងមួយឆ្នាំអាស្រ័យលើការថែទាំ។ លក្ខខណ្ឌចាំបាច់សម្រាប់ជំរុញឱ្យចេញផ្កាបានគឺការផ្ដល់ទឹក និងជីបានត្រឹមត្រូវ។



ការកាត់តែងមែក បូតស្លឹក ចេញផ្កា និងផ្លែ

### ៣.៧-ការគ្រប់គ្រងសត្វល្អិត

សត្វល្អិតដែលបំផ្លាញលើដំណាំទៀបមានច្រើនប្រភេទ។ សត្វល្អិតដែលតែងជួបប្រទះញឹកញាប់ជាងគេលើដំណាំទៀបមានដូចជា ចៃស ចៃក្រមួន ដង្កូវចោះផ្លែ និងរុយទិចផ្លែ ។ ការគ្រប់គ្រងសត្វល្អិតបានល្អ ជួយបន្ថយជំងឺ(ដែលភាគច្រើនសត្វល្អិតជាភ្នាក់ងារចម្លង) និងបង្កើនទិន្នផល។

**៣.៧.១-ចៃស (Mealybug)**÷ជាពពួកតោងស្អិតទៅនឹងផ្ទៃ ស្លឹក ត្រួយខ្ចីផ្នែកខាងក្រោមដែលទើបលាស់ថ្មីហើយបឺតរុក្ខរសរបស់ស្លឹក ផ្លែ ស្រទាប់ផ្កា បន្ថយការលូតលាស់ដំណាំទៀប នាំឱ្យខូចទ្រង់ទ្រាយស្លឹក ផ្កា ផ្លែ និងនាំឱ្យជ្រុះ។ **វិធានការ÷**កាត់ស្លឹកដែលមានចៃនេះយកទៅបំផ្លាញចោលដើម្បីបង្ការការ

ឆ្លងទៅស្លឹកផ្សេងៗទៀត។ ក្នុងករណីមានការបំផ្លាញច្រើនអាចប្រើថ្នាំគីមីដោយមានការណែនាំពីអ្នកជំនាញ ដូចជាថ្នាំ Imidacloprid ឬថ្នាំផ្សេងៗទៀត។

**៣.៧.២-ចៃក្រមួន (Scales)÷** ជាពពួកសត្វល្អិតបឺតជញ្ជក់យករុក្ខរសលើផ្ទៃស្លឹក ផ្លែ ត្រួយខ្ចី ដែលអាចធ្វើឱ្យស្លឹកទៀបរួញ។ វិធានការ÷ កសិករអាចប្រើថ្នាំផ្សំពីធម្មជាតិដើម្បីបណ្តេញ ក្នុងករណីមានការបំផ្លាញតិច និងកាត់មែកមានចៃទៅបំផ្លាញចោល។ បើមានការបំផ្លាញច្រើនខ្លាំង កសិករអាចប្រើថ្នាំគីមីដោយមានការណែនាំពីអ្នកជំនាញ ដូចជា Thiamethoxam និង Imidacloprid។

**៣.៧.៣-ដង្កូវចោះផ្លែ (Fruit Borer/ Fruit boring caterpillar)÷**កសិករត្រូវឧស្សាហ៍ត្រួតពិនិត្យចម្ការជាប្រចាំ អង្កេតមើលប្រភេទមេអំបៅដែលហើរនៅក្នុងចម្ការទៀបព្រោះជាប្រភពដង្កូវ។ មេអំបៅនឹងទៅបញ្ចេញពងលើផ្លែដែលជិតល្មមប្រមូលផល រួចពងរបស់វាក៏ញាស់ជាដង្កូវស៊ីផ្លែទៀប។ វិធានការ÷ ១)ការស្រោបផ្លែជាវិធីសាស្ត្រល្អបំផុតដោយចាប់ផ្តើមស្រោបផ្លែទៀបជាមួយ ថង់ក្រដាស ថង់ផ្លាស្ទិក ឬថង់សំណាញ់មុងឱ្យបានលឿនបំផុតនៅពេលផ្លែមានទំហំប៉ុនមេដៃ ២)ត្រូវដើរពិនិត្យចម្ការឱ្យបានទៀងទាត់ និងត្រូវបេះផ្លែដែលមានការបំផ្លាញទៅដុតចោល ឬកប់ចោលភ្លាមៗ ដើម្បីកុំឱ្យវាទៅបំផ្លាញផ្លែផ្សេងទៀត ៣)ប្រើប្រភេទថ្នាំប៉ះផ្ទាល់ Abamectin និង Spinosad។

**៣.៧.៤-រុយចោះផ្លែ (Fruit Fly)÷** រុយញី១ក្បាលអាចបញ្ចេញពងបានជាង ៣,០០០ ពង ក្នុងមួយវដ្តជីវិតរបស់វា តែពេលខ្លះអាចនៅចន្លោះ ១,២០០-១,៥០០ ពង។ ពីកូនញាស់ដល់ដឹកដឿ ៩ថ្ងៃ និងពីដុកដឿដល់ពេញវ័យ ត្រូវការពេលវេលា ៧ ថ្ងៃនៅលក្ខខណ្ឌរដូវក្តៅ។ វិធានការ÷១)ការវេចខ្ចប់ផ្លែនៅពេលផ្លែទៀបមានទំហំប៉ុន ៣ ស.ម ដោយប្រើថង់ដែលមានចោះរន្ធតូចៗឱ្យខ្យល់ចេញចូល ឬស្បៃមុងដើម្បីស្រោបផ្លែ ២) ត្រូវរើសផ្លែដែលរលួយ ឬផ្លែដែលធ្លាក់ចុះមកដីយកទៅដុតចោល ឬកប់ក្នុងដីឱ្យជ្រៅយ៉ាងតិច ០.៥ ម៉ែត្រដើម្បីកម្ចាត់ដង្កូវដែលនៅក្នុងផ្លែ កុំឱ្យវាក្លាយជាដង្កូវដឹកដឿក្នុងដី ៣)ប្រើអន្ទាក់មេទីល អឺហ្សីណុល (Methyl Eugenol) សម្រាប់ទាក់ទាញរុយឈ្មោលឱ្យមកជាប់អន្ទាក់ អាចជួយកាត់បន្ថយការបង្កកំណើតបានយ៉ាងច្រើន ៤)បើការរាតត្បាតខ្លាំង អ្នកអាចប្រើប្រាស់ថ្នាំកសិកម្មដែលមានសារធាតុសកម្មដូចជា Deltamethrin ឬ Cypermethrin។



ចៃសនៅខ្នងស្លឹក និងផ្លែទៀប




ចៃក្រមួនលើស្លឹក និងផ្លែទៀប



ដង្កូវចោះផ្លែទៀប



រុយទិចផ្លែទៀប

### ៣.៨.- ការគ្រប់គ្រងជំងឺ

ការកាត់ស្លឹកណាដែលងាប់ ខូចខាត ឬមានរោគសញ្ញាជំងឺចេញជាប្រចាំ ដើម្បីកាត់បន្ថយការរីករាលដាល និងយកកាកសំណល់រុក្ខជាតិដែលងាប់ងាយបង្កជាជំងឺចេញពីចម្ការ។ ជំងឺទៀបដែលកសិករតែងតែជួបប្រទះជំងឺលើដំណាំទៀប ភាគច្រើនបណ្តាលមកពីការគ្រប់គ្រងទឹក និងជីជាតិមិនបានល្អ។

**៣.៨.១- ជំងឺអង់ត្រាក់ណូស (Anthracnose)÷** ជំងឺនេះមានរោគសញ្ញាដោយឃើញស្នាមអុចពណ៌ពីត្នោតទៅខ្មៅ (កោសិកាងាប់) ពាសពេញលើផ្លែ និងស្លឹក ដែលបណ្តាលឱ្យជ្រុះ។ ជំងឺអង់ត្រាក់ណូសអាចបង្កើនការរាលដាលលឿន និងខ្ពស់ក្នុងលក្ខខណ្ឌសំណើមខ្ពស់ និងខ្យល់បក់។ កាកសំណល់ផ្លែ និងស្លឹកចាស់ៗ គឺប្រភពចម្លងសំខាន់ទៅដើមផ្សេងៗនៅក្នុងចម្ការ។ វិធានការ÷ ១) ត្រូវកាត់តែងមែកមួយចំនួនដើម្បីឱ្យមានពន្លឺថ្ងៃចាំងចូលគ្រប់គ្រាន់ ខ្យល់ចេញចូលបានល្អ និងកាត់មែកដែលឆ្លងជំងឺ រួចយកទៅដុតចោលឱ្យឆ្ងាយពីចម្ការ ២) ប្រមូលផ្លែដែលរលួយ និងស្លឹកជ្រុះដែលមានផ្ទុកមេរោគផ្សិតនៅលើដីទៅដុតកម្ទេចចោល ៣) កុំស្រោចទឹកដែលធ្វើឱ្យសើមដល់ស្លឹក ឬផ្លែខ្លាំងពេក ជាពិសេសនៅពេលល្ងាច នាំឱ្យងាយឆ្លងជំងឺ ៤) កុំប្រើជីអាសូត (N) ច្រើនហួសប្រមាណ ដែលធ្វើឱ្យស្លឹក និងផ្លែទន់ ងាយរងការវាយប្រហារពីមេរោគ និងគួរបង្កើនជីប៉ូតាស្យូម (K) និងកាល់ស្យូម (Ca) ដើម្បីពង្រឹងកោសិកាដើម ស្លឹក ផ្កា និងផ្លែ ៥) ប្រើ Manconzeb សម្រាប់បាញ់បង្ការនៅពេលមេឃចាប់ផ្តើមមានសំណើមខ្ពស់ និងប្រើ Azoxystrobin + Difenoconazole មានប្រសិទ្ធភាពខ្ពស់ទាំងបង្ការ និងកម្ចាត់។

**៣.៨.២- ជំងឺអុចស្លឹក (Leave Spot)÷** ជំងឺអុចស្លឹកទៀបបង្កឡើងដោយមេរោគផ្សិតឈ្មោះ Cylindrocladium ដែលធ្វើឱ្យស្លឹកឡើងអុចៗ និងរលាកខ្លាំង។ ចំណែកផ្សិតAlternaria ធ្វើឱ្យស្លឹកឡើងអុចខ្មៅមានរង្វង់ៗលើដំណាំទៀបផងដែរ។ បញ្ហានេះតែងតែកើតមាននៅពេលអាកាសធាតុមានសំណើមខ្ពស់ និងភ្លៀងធ្លាក់ច្រើន។ វិធានការ÷ ១) ត្រូវកាត់មែកបង្កើនខ្យល់ចេញចូលដើម្បីកាត់បន្ថយសំណើមដែលជាកត្តាជំរុញឱ្យផ្សិតលូតលាស់ ២) ប្រើជីសរីរាង្គដែលមានសមាសធាតុផ្សំពីផ្សិត Trichoderma ដើម្បីជួយទប់ស្កាត់មេរោគក្នុងដី និងបង្កើនជីកាល់ស្យូម-បរ(Ca-B) ដើម្បីឱ្យកោសិកាស្លឹកមានភាពរឹងមាំ

៣) ប្រើ Mancozeb និង Chlorothalonil សម្រាប់ការពារ-បង្ការ និង Difenoconazole + Azoxystrobin សម្រាប់ព្យាបាលនិងទប់ស្កាត់ការរាលដាលលឿន និងថ្នាំ Tebuconazole មានប្រសិទ្ធភាពខ្ពស់ទៅលើផ្សិតក្រុម Alternaria។

**៣.៨.៣-ជំងឺរលួយឌីផ្លូឌីយ៉ា (Diplodia)÷** ជំងឺរលួយផ្លែ និងមែកដែលបង្កឡើងដោយផ្សិត Diplodia ឈ្មោះពេញ *Lasiodiplodia theobromae*) គឺជាជំងឺដ៏កាចសាហាវមួយលើដំណាំទៀប។ វាបង្កឱ្យមានការរលួយខ្មៅចេញពីទងផ្លែ ឬគូទផ្លែ និងធ្វើឱ្យមែកក្រៀមងាប់ (Dieback) ដែលប៉ះពាល់ធ្ងន់ធ្ងរដល់គុណភាពផ្លែពេលប្រមូលផល។ នៅពេលវាកើតលើផ្លែ ការរលួយមានពណ៌ត្នោត ឬខ្មៅ ចេញពីកន្លែងដែលមានរបួស ឬចេញពីទងផ្លែ រួចរាលដាលសព្វផ្លែយ៉ាងលឿន សាច់ផ្លែទៀបទន់ជ្រាយ និងក្លិនជូរ។ បើកើតលើមែក ការចាប់ផ្តើមក្រៀមស្ងួតពីចុងមកគល់ (Dieback) ហើយសំបកមែកអាចមានសភាពប្រេះ ឬហៀរជ័រ។ **វិធានការ÷** ១) កាត់មែកដែលស្ងួតងាប់ចោល ដោយកាត់ឱ្យកៀកនឹងដើមមេ និងប្រមូលផ្លែដែលរលួយ និងមែកងាប់យកទៅដុតចោលឱ្យអស់ ២) ការពារការមានស្នាមរបួសលើផ្លែ ឬមែក នៅពេលថែទាំ និងរបួសដែលបង្កដោយសត្វល្អិត (ដូចជាជញ្ជក់ទងផ្លែ) គឺជាច្រកចូលដ៏ធំរបស់មេរោគ ៣) Thiophanate-methyl មានប្រសិទ្ធភាពខ្លាំងក្នុងការទប់ស្កាត់ផ្សិត Diplodia ប្រើ Carbendazim ជួយព្យាបាល និងការពារការរាលដាលមេរោគក្នុងជាលិការុក្ខជាតិ និង Azoxystrobin សម្រាប់បាញ់ការពារមុនពេលប្រមូលផល ដើម្បីកាត់បន្ថយការរលួយនៅពេលផ្លែទុំ(ប្រើតាមការណែនាំ)។

**៣.៨.៤-ជំងឺដំបៅពណ៌ខ្មៅ÷** ជំងឺដំបៅខ្មៅ (Black Canker) ដែលបង្កឡើងដោយផ្សិតម្យ៉ាងឈ្មោះ *Phomopsis anonacearum* គឺជាជំងឺមួយដែលអាចធ្វើឱ្យខូចគុណភាពផ្លែយ៉ាងធ្ងន់ធ្ងរ និងធ្វើឱ្យមែកក្រៀមងាប់។ ជំងឺនេះច្រើនកើតមានខ្លាំងនៅពេលអាកាសធាតុក្តៅស្ងួះស្ងាប់ និងមានសំណើមខ្ពស់។ ស្នាមអុចពណ៌ត្នោតតូចៗ រួចរាលដាលជាដំបៅខ្មៅ រឹង និងស្រុតចូលទៅក្នុងសាច់ផ្លែ។ ជួនកាលផ្លែដែលឆ្លងជំងឺនឹងស្ងួតរឹងជាប់នឹងមែក (Mummified fruit)។ មែក និងដើមមានលេចចេញជាដំបៅពណ៌ខ្មៅប្រេះសំបក និងអាចហៀរជ័រ។ ប្រសិនបើមានរាលដាលជុំវិញមែក នឹងធ្វើឱ្យស្លឹកនៅលើមែកនោះឡើងពណ៌លឿង និងក្រៀមងាប់ពីចុងមក។ **វិធានការ÷** ១) ត្រូវកាត់មែកដែលមានដំបៅខ្មៅចេញ បេះផ្លែដែលស្ងួតខ្មៅជាប់មែកចេញឱ្យអស់ និងយកទៅដុតចោលព្រោះវាជាកន្លែងផ្ទុកស្ព័រផ្សិត ២) ក្រោយពេលកាត់មែករួចរាល់ គួរបាញ់ថ្នាំសម្លាប់មេរោគផ្សិតដែលមានជាតិទង់ដែង (Copper Hydroxide , Copper Oxychloride) ឱ្យសព្វដើម និងមែក ដើម្បីកម្ចាត់ស្ព័រផ្សិតដែលលាក់ខ្លួនតាមសំបក ៣) ប្រើ Mancozeb សម្រាប់បាញ់ការពារជារៀងរាល់ ៧-១០ ថ្ងៃម្តង នៅរដូវភ្លៀង និង Captan មានប្រសិទ្ធភាពល្អក្នុងការទប់ស្កាត់ជំងឺដំបៅខ្មៅលើផ្លែ ចំណែក Prochloraz, Carbendazim, Thiophanate-methyl, Difenoconazole សម្រាប់ព្យាបាល ដើម មែក ស្លឹក និងផ្លែ។





ជំងឺអង់ត្រាក់ណូសលើស្លឹក ផ្លែ និងចុងមែក

ជំងឺអុចស្លឹក (Leave Spot)





ជំងឺរលួយឌីផ្លូឌីយ៉ា (Diplodia)

ជំងឺដំបៅពណ៌ខ្មៅ(Black Canker)

## ៤-ការប្រមូលផល

**៤.១-លក្ខណៈផ្លែចាស់÷** ជាធម្មតា ការប្រមូលផលទៀបចាប់ផ្តើមនៅក្នុងខែតុលា និងបញ្ចប់នៅក្នុងខែវិច្ឆិកា។ ផ្លែទៀបត្រូវបានបេះប្រមូលផលពី ២ ទៅ ៣ ដង។ ដំណាំទៀបចាប់ផ្តើមចេញផ្កាពីឆ្នាំទី ២-៣ ក្រោយដាំ ហើយអាចប្រមូលផលផ្លែមួយចំនួន។ បើគិតចាប់បែកផ្ការហូតដល់ផ្លែទុំមានរយៈពេល ៣-៤ខែ។ កសិករអាចប្រមូលផលបាននៅពេលក្រឡារបស់ផ្លែរីកធំ ហើយមានគម្លាតពីគ្នា។

**៤.២-ការដាក់បន្ទុំ÷** ផ្លែទៀបអាចទុំ ២-៤ ថ្ងៃបន្ទាប់ពីបេះពីដើម។ បើក្រឡាផ្លែរីកកាន់តែធំ ទៀបនឹងកាន់តែឆាប់ទុំ។ ផ្លែទៀបដែលទុំហើយងាយនឹងខូច មិនអាចទុកយូរបានទេ មិនត្រូវដាក់គរលើគ្នាទេ ព្រោះនាំឱ្យជាំ និងឆាប់ខូចគុណភាព។







លក្ខណៈផ្លែចាស់ និងទុំ

**៤.៣-ទិន្នផលទៀបស្វិតតាមអាយុកាល÷** ដើមទៀបចាប់ផ្ដើមឱ្យផលពេញលេញនៅពេលមានអាយុពេញ ៥ឆ្នាំ។ តារាងខាងក្រោមបង្ហាញពីបរិមាណទិន្នផលជាមធ្យមតាមឆ្នាំនីមួយៗ តាមអាយុកាល។

| អាយុកាលដើមទៀប | កម្រិតទិន្នផល (ទាប-ខ្ពស់) គ.ក្រ | ទិន្នផលជាមធ្យម គ.ក្រ/ហិកតា |
|---|---|---|
| ឆ្នាំទី ២ (ចាប់ផ្ដើមហុចផល) | 2,000 – 4,000 | 3,000 |
| ឆ្នាំទី ៣ (ផលកើនឡើង) | 5,000- 7,000 | 6,000 |
| ឆ្នាំទី ៤ (ផលបន្តកើន) | 7,000- 9,000 | 8,000 |
| ឆ្នាំទី ៥ (ផលពេញលេញ) | 9,000 – 11,000 | 10,000 |
| ឆ្នាំទី ៦ (ផលពេញលេញ) | 13,000 – 15,000 | 14,000 |

## ៥-ការវិភាគសេដ្ឋកិច្ចលើការដាំដំណាំទៀបលើផ្ទៃដី១ហិកតា

### ៥.១-តារាងវិភាគសេដ្ឋកិច្ចលើការដាំដុះដំណាំទៀបស្វិតក្នុង១ហិកតា÷

គម្លាតដើម ៤ម៉ែត្រ និងគម្លាតជួរ ៥ម៉ែត្រ ចំនួន៥០០ដើមក្នុង១ហិកតា

| បរិយាយ | ឯកតា | បរិមាណ | តម្លៃ/ឯកតា (រៀល) | តម្លៃសរុប (រៀល) |
|---|---|---|---|---|
| **I- ចំណាយចាប់ផ្ដើមដំបូង (I.ក+I.ខ+I.គ)** | | | | **27,148,000** |
| **I.ក-ចំណាយសម្អាតចម្ការ និងដាំដុះ** | | | | **7,410,000** |
| ការសម្អាតដីចម្ការ | ហ.ត | 1 | 800,000 | 800,000 |
| ឈ្នួលភ្ជួរដី | ហ.ត | 2 | 200,000 | 400,000 |
| ជីកំប៉ុសទ្រាប់បាត | គ.ក | 2,500 | 1,000 | 2,500,000 |
| គីមីទ្រាប់បាត | គ.ក | 50 | 3,200 | 160,000 |
| កំបោរកសិកម្មទ្រាប់បាត | គ.ក | 50 | 1,000 | 50,000 |
| កូនពូជ | ដើម | 500 | 4,000 | 2,000,000 |
| ឈ្នួលជីករណ្ដៅ ទ្រាប់បាត និងដាំ | រណ្ដៅ | 500 | 3,000 | 1,500,000 |
| **I.ខ-ចំណាយរៀបប្រព័ន្ធទឹក (ចំណាយមិនប្រែប្រួល)** | | | | **12,800,000** |
| ចំណាយលើការរំលស់ការរៀបចំប្រព័ន្ធទឹករួមទាំងម៉ាស៊ីន | ឈុត | 1 | 12,000,000 | 12,000,000 |
| ប្រព័ន្ធលាយជីទឹកតាមទុយោ | ឈុត | 1 | 800,000 | 800,000 |
| **I.គ-ចំណាយថែទាំឆ្នាំទី១** | | | | **6,938,000** |
| កម្លាំងពលកម្មដាក់ជី ស្រោចទឹក | នាក់/ថ្ងៃ | 33 | 30,000 | 990,000 |
| ឈ្នួលជម្រះស្មៅក្រោយដាំ | ដង | 3 | 300,000 | 900,000 |
| ជីបំប៉នការលូតលាស់ (ជីសរីរាង្គ) | គ.ក្រ | 2,500 | 1,000 | 2,500,000 |

| | | | | |
|---|---|---|---|---|
| ជីបំប៉នការលូតលាស់ (ជី NPK) | គ.ក្រ | 100 | 2,500 | 250,000 |
| ថ្នាំការពារសត្វល្អិត និងជំងឺ | ដង | 6 | 33,000 | 198,000 |
| ចំណាយបូមទឹកស្រោច(ប្រេងម៉ាស៊ូត) | លីត្រ | 400 | 5,000 | 2,000,000 |
| ចំណាយផ្សេងៗ | ឆ្នាំ | 1 | 100,000 | 100,000 |
| **II-ចំណាយថែទាំឆ្នាំទី ២** | | | | **12,900,000** |
| កម្លាំងពលកម្មដាក់ជី ស្រោចទឹក | នាក់/ថ្ងៃ | 66 | 30,000 | 1,980,000 |
| ថ្នាំកម្ចាត់ស្មៅ | ដង | 3 | 80,000 | 240,000 |
| ជីបំប៉នការលូតលាស់ (ជីសរីរាង្គ) | គ.ក្រ | 5,000 | 1,000 | 5,000,000 |
| ជីបំប៉នការលូតលាស់ (ជី NPK) | គ.ក្រ | 200 | 2,500 | 500,000 |
| កំបោរកសិកម្មបាចជុំវិញគល់ | គ.ក | 100 | 1,000 | 100,000 |
| ថ្នាំការពារសត្វល្អិត និងជំងឺ | ដង | 6 | 40,000 | 240,000 |
| កម្មករកាត់មែកខ្នែងទៀប | នាក់ | 8 | 30,000 | 240,000 |
| ឈ្នួលសម្អាតតាមគល់ | ដើម | 500 | 2,000 | 1,000,000 |
| ចំណាយបូមទឹកស្រោច(ប្រេងម៉ាស៊ូត) | លីត្រ | 500 | 5,000 | 2,500,000 |
| ឈ្នួលពលកម្មបេះផ្លែទៀប ឆ្នាំទី២ | គ.ក្រ | 3,000 | 200 | 600,000 |
| ចំណាយផ្សេងៗ | ឆ្នាំ | 1 | 100,000 | 100,000 |
| ទិញកញ្ចេសម្រាប់ប្រមូលផល | ២០កញ្ចេ | 1 | 400,000 | 400,000 |
| **ចំណូលពីលក់ផ្លែទៀប/ហិកតា** | **គ.ក** | 3,000 | 5,000 | **15,000,000** |
| **លទ្ធផលបង្គរត្រឹមឆ្នាំទី២ ចំណូលឆ្នាំទី២** -(I+II+III) | | | | **-25,048,000** |
| **III-ចំណាយថែទាំឆ្នាំទី ៣** | | | | **16,390,000** |
| កម្លាំងពលកម្មដាក់ជី ស្រោចទឹក | នាក់/ថ្ងៃ | 75 | 30,000 | 2,250,000 |
| ថ្នាំកម្ចាត់ស្មៅ | ដង | 3 | 80,000 | 240,000 |
| ជីបំប៉នការលូតលាស់ (ជីសរីរាង្គ) | គ.ក្រ | 7,500 | 1,000 | 7,500,000 |
| ជីបំប៉នការលូតលាស់ (ជីNPK) | គ.ក្រ | 200 | 2,500 | 500,000 |
| កំបោរកសិកម្មបាចជុំវិញគល់ | គ.ក | 100 | 1,000 | 100,000 |
| ថ្នាំការពារសត្វល្អិត និងជំងឺ | ដង | 8 | 40,000 | 320,000 |
| កម្មករកាត់មែកខ្នែងទៀប | នាក់ | 6 | 30,000 | 180,000 |
| ឈ្នួលសម្អាតតាមគល់ | ដើម | 500 | 2,000 | 1,000,000 |
| ចំណាយបូមទឹកស្រោច(ប្រេងម៉ាស៊ូត) | លីត្រ | 600 | 5,000 | 3,000,000 |
| ឈ្នួលពលកម្មបេះផ្លែទៀប ឆ្នាំទី៣ | គ.ក្រ | 6,000 | 200 | 1,200,000 |
| ចំណាយផ្សេងៗ | ឆ្នាំ | 1 | 100,000 | 100,000 |

| | | | | |
|---|---|---|---|---|
| **ចំណូលពីលក់ផ្លែទៀប/ហិកតា** | **គ.ក** | 6,000 | 5,000 | **30,000,000** |
| **លទ្ធផលបង្គរខាត-ចំណេញត្រឹមឆ្នាំទី៣**(ចំណូលឆ្នាំទី៣ - លទ្ធផលបង្គរខាត ចំណេញ ត្រឹមឆ្នាំទី២) | | | | **-11,438,000** |
| **IV-ចំណាយថែទាំឆ្នាំទី ៤** | | | | **21,250,000** |
| កម្លាំងពលកម្មដាក់ជី ស្រោចទឹក | នាក់/ថ្ងៃ | 132 | 30,000 | 3,960,000 |
| ថ្នាំកម្ចាត់ស្មៅ | ដង | 3 | 80,000 | 240,000 |
| ជីបំប៉នការលូតលាស់ (ជីសរីរាង្គ) | គ.ក្រ | 10,000 | 1,000 | 10,000,000 |
| ជីបំប៉នការលូតលាស់ (ជី NPK) | គ.ក្រ | 500 | 2,500 | 1,250,000 |
| កំបោរកសិកម្មបាចជុំវិញគល់ | គ.ក | 100 | 1,000 | 100,000 |
| ថ្នាំការពារសត្វល្អិត និងជំងឺ | ដង | 8 | 40,000 | 320,000 |
| កម្មករកាត់មែកខ្នែងទៀប | ដង | 6 | 30,000 | 180,000 |
| ឈ្នួលសម្អាតតាមគល់ | ដើម | 500 | 1,000 | 500,000 |
| ចំណាយបូមទឹកស្រោច(ប្រេងម៉ាស៊ូត) | លីត្រ | 600 | 5,000 | 3,000,000 |
| ឈ្នួលពលកម្មបេះផ្លែទៀប ឆ្នាំទី៤ | គ.ក្រ | 8,000 | 200 | 1,600,000 |
| ចំណាយផ្សេងៗ | ឆ្នាំ | 1 | 100,000 | 100,000 |
| **ចំណូលពីលក់ផ្លែទៀប/ហិកតា** | **គ.ក** | 8,000 | 5,000 | **40,000,000** |
| **លទ្ធផលបង្គរខាត-ចំណេញត្រឹមឆ្នាំទី៤** (ចំណូលឆ្នាំទី៤ - លទ្ធផលបង្គរខាត ចំណេញត្រឹមឆ្នាំទី៣ ) | | | | **7,312,000** |
| **V-ចំណាយថែទាំឆ្នាំទី ៥** | | | | **28,390,000** |
| កម្លាំងពលកម្ម បូតស្លឹក ដាក់ជី និងស្រោចទឹក | នាក់/ថ្ងៃ | 165 | 30,000 | 4,950,000 |
| ថ្នាំកម្ចាត់ស្មៅ | ដង | 3 | 80,000 | 240,000 |
| ជីបំប៉នការលូតលាស់ (ជីសរីរាង្គ) | គ.ក្រ | 15,000 | 1,000 | 15,000,000 |
| ជីបំប៉នការលូតលាស់ (ជីNPK) | គ.ក្រ | 600 | 2,500 | 1,500,000 |
| កំបោរកសិកម្មបាចជុំវិញគល់ | គ.ក | 100 | 1,000 | 100,000 |
| ថ្នាំការពារសត្វល្អិត និងជំងឺ | ដង | 8 | 40,000 | 320,000 |
| កម្មករកាត់មែកខ្នែងទៀប | ដង | 6 | 30,000 | 180,000 |
| ឈ្នួលសម្អាតតាមគល់ | ដើម | 500 | 2,000 | 1,000,000 |
| ចំណាយបូមទឹកស្រោច(ប្រេងម៉ាស៊ូត) | លីត្រ | 600 | 5,000 | 3,000,000 |
| ឈ្នួលពលកម្មបេះផ្លែទៀប | គ.ក្រ | 10,000 | 200 | 2,000,000 |
| ចំណាយផ្សេងៗ | ឆ្នាំ | 1 | 100,000 | 100,000 |
| **ចំណូលពីលក់ផ្លែទៀប/ហិកតា** | **គ.ក** | 10,000 | 5,000 | **50,000,000** |
| **លទ្ធផលបង្គរខាត-ចំណេញត្រឹមឆ្នាំទី៥** (ចំណូលឆ្នាំទី៥ + លទ្ធផលបង្គរខាតចំណេញត្រឹមឆ្នាំទី៤ ) | | | | **28,922,000** |
| **VI-ចំណាយថែទាំឆ្នាំទី៦** | | | | **35,430,000** |
| កម្លាំងពលកម្ម បូតស្លឹក និងដាក់ជី | នាក់/ថ្ងៃ | 198 | 30,000 | 5,940,000 |

| | | | | |
|---|---|---|---|---|
| ថ្នាំកម្ចាត់ស្មៅ | ដង | 3 | 80,000 | 240,000 |
| ជីបំប៉នការលូតលាស់ (ជីសរីរាង្គ) | គ.ក្រ | 20,000 | 1,000 | 20,000,000 |
| ជីបំប៉នការលូតលាស់ (ជីNPK) | គ.ក្រ | 700 | 2,500 | 1,750,000 |
| កំបោរកសិកម្មបាចជុំវិញគល់ | គ.ក | 100 | 1,000 | 100,000 |
| ថ្នាំការពារសត្វល្អិត និងជំងឺ | ដង | 8 | 40,000 | 320,000 |
| កម្មករកាត់មែកខ្នែងទៀប | ដង | 6 | 30,000 | 180,000 |
| ឈ្នួលសម្អាតតាមគល់ | ដើម | 500 | 2,000 | 1,000,000 |
| ចំណាយបូមទឹកស្រោច(ប្រេងម៉ាស៊ីន) | លីត្រ | 600 | 5,000 | 3,000,000 |
| ឈ្នួលពលកម្មបេះផ្លែទៀប | គ.ក្រ | 14,000 | 200 | 2,800,000 |
| ចំណាយផ្សេងៗ | ឆ្នាំ | 1 | 100,000 | 100,000 |
| **ចំណូលពីលក់ផ្លែទៀប/ហិកតា** | **គ.ក** | 14,000 | 5,000 | **70,000,000** |
| **លទ្ធផលបង្គរចំណេញ-ខាតត្រឹមឆ្នាំទី៦**(ចំណូលឆ្នាំទី៦ + លទ្ធផលបង្គរខាត ចំណេញត្រឹមឆ្នាំទី៥ ) | | | | **63,492,000** |

## ៥.២- តារាងសង្ខេបពីចំណេញ-ខាត

| ឆ្នាំ | ទិន្នផល (គ.ក្រ/ហ.ត/ឆ្នាំ) | តម្លៃ/គ.ក្រ (រៀល) | ចំណូលសរុប (រៀល) | ចំណាយសរុប (រៀល) | ចំណាយបង្គរ (រៀល) | លទ្ធផល ចំណេញ-ខាត (រៀល) |
|---|---|---|---|---|---|---|
| ឆ្នាំទី១ | - | - | - | 27,148,000 | | |
| ឆ្នាំទី២ | 3,000 | 5,000 | 15,000,000 | 12,900,000 | 40,048,000 | -25,048,000 |
| ឆ្នាំទី៣ | 6,000 | 5,000 | 30,000,000 | 16,390,000 | -41,438,000 | -11,438,000 |
| ឆ្នាំទី៤ | 8,000 | 5,000 | 40,000,000 | 21,250,000 | -32,688,000 | 7,312,000 |
| ឆ្នាំទី៥ | 10,000 | 5,000 | 50,000,000 | 28,390,000 | | 21,610,000 |
| ឆ្នាំទី៦ | 14,000 | 5,000 | 70,000,000 | 35,430,000 | | 34,570,000 |

ដំណាំទៀបស្វិតអាចទទួលផលចំណេញនៅឆ្នាំទី៤ បើទិន្នផលដូចតារាងខាងលើនេះ។

### ៥.៣-ថ្លៃដើមផលិតកម្មក្នុង១គីឡូក្រាម

ចំណាយចាប់ផ្តើមនិងឆ្នាំទី១ ជាចំណាយបង្កើតចម្ការ សម្រាប់ដាំដុះទៀបដែលមានវដ្តជីវិត ២០ឆ្នាំ÷

| ឆ្នាំទទួលផល | ចំណាយ | ចំណាយបង្កើតចម្ការ ផ្តើមដំបូង និងឆ្នាំទី១ (ចែកនឹង២០ឆ្នាំ) | ចំណាយសរុប (រៀល) | ទិន្នផល (គ.ក្រ) | ថ្លៃដើម/គីឡូក្រាម (រៀល) |
|---|---|---|---|---|---|
| ឆ្នាំទី២ | 12,900,000 | 1,357,400 | 14,257,400 | 3,000 | 4,752 |
| ឆ្នាំទី៣ | 16,390,000 | 1,357,400 | 17,747,400 | 6,000 | 2,958 |
| ឆ្នាំទី៤ | 21,250,000 | 1,357,400 | 22,607,400 | 8,000 | 2,826 |
| ឆ្នាំទី៥ | 28,390,000 | 1,357,400 | 29,747,400 | 10,000 | 2,975 |
| ឆ្នាំទី៦ | 35,430,000 | 1,357,400 | 36,787,400 | 14,000 | 2,628 |
| ថ្លៃដើមជាមធ្យម/គ.ក្រ (រៀល) | | | | | **3,228** |

## ៦- ហានិភ័យ បញ្ហាប្រឈម និងដំណោះស្រាយ

ហានិភ័យចំពោះផលិតកម្មដំណាំទៀបដែលកសិករអាចនឹងជួបប្រទះក្នុងកំឡុងពេលដាំដំណាំទៀប÷

| ប្រភេទហានិភ័យ | បញ្ហាប្រឈម | ដំណោះស្រាយ |
|---|---|---|
| **ហានិភ័យ ផលិតកម្ម** | **-ជំងឺផ្សិត÷** ជំងឺផ្សិតដើម ស្លឹក និងផ្លែដែលអាចបន្ថយទិន្នផល។ **-សត្វល្អិត÷** ដែលអាចធ្វើឱ្យខូចខាតដល់ដំណាំ និងកាត់បន្ថយទិន្នផលផ្លែទៀប។ | -ការគ្រប់គ្រងជំងឺទាមទារចំណេះដឹង និងការយកចិត្តទុកដាក់ខ្ពស់ជាប្រចាំដោយពិភាក្សាជាមួយអ្នកជំនាញ ដើម្បីប្រើប្រាស់វិធីសាស្ត្របង្ការ និងកម្ចាត់ឱ្យបានត្រឹមត្រូវ។ -ជ្រើសរើសពូជដែលធន់នឹងជំងឺ និងសមស្របនឹងអាកាសធាតុ និងដីក្នុងតំបន់ដាំដុះ -តាមដាននិងគ្រប់គ្រងសត្វល្អិត÷ បំបាត់ជម្រកនិងប្រើប្រាស់ថ្នាំកសិកម្មដែលមានប្រសិទ្ធភាព និងសុវត្ថិភាព តាមការណែនាំរបស់អ្នកជំនាញ។ |
| | **-គ្រោះរាំងស្ងួត÷** អាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការលូតលាស់ និងអាចបណ្តាលឱ្យដើមទៀបងាប់ដើម។ **-ទឹកជំនន់÷** អាចធ្វើឱ្យដើមទៀបជាំទឹក និងងាប់បាន បើមិនអាចបង្ហូរទឹកចេញឱ្យទាន់ពេលវេលា។ | គ្រប់គ្រងប្រព័ន្ធធារាសាស្ត្រឱ្យបានល្អ÷ -បង្កើតប្រភពទឹក និងខួងអណ្តូងយកទឹកក្រោមដីមកប្រើប្រាស់។ -ទីតាំងដាំដុះគប្បីជាដីទួលមិនលិចទឹក -ជីកប្រព័ន្ធបង្ហូរទឹក សម្រាប់ដំណាំទៀប |

| | | |
|---|---|---|
| | **-គុណភាពដី÷**<br>ដីខ្សោះជីជាតិ និង កង្វះសារធាតុចិញ្ចឹមអាចធ្វើឱ្យទៀបលូតលាស់មិនបានល្អ និងងាយរងការបំផ្លាញពីសត្វល្អិត និងជំងឺ។ | -ធ្វើតេស្តគុណភាពដី រាល់១-២ឆ្នាំម្តង ដើម្បីកែតម្រូវសារធាតុចិញ្ចឹមចាំបាច់ឱ្យដី<br>-ប្រើប្រាស់កំបោរកសិកម្ម ជីកំប៉ុស និងជីសរីរាង្គផ្សេងទៀត |
| **ហានិភ័យទីផ្សារ** | **-តម្រូវការ÷**<br>តម្លៃផ្លែទៀបអាចប្រែប្រួលទៅតាមរដូវកាល ឬតម្រូវការទីផ្សារ។ ប្រសិនបើតម្លៃធ្លាក់ចុះ វាអាចធ្វើឱ្យកសិករខាតបង់។<br>**-ការប្រកួតប្រជែង÷**<br>ការប្រកួតប្រជែងពីអ្នកដាំដុះផ្សេងឬការនាំចូលពីប្រទេសិតខាងក៏អាចជះឥទ្ធិពលដល់តម្លៃទីផ្សារផងដែរ។ | -ស្វែងយល់ពីតម្រូវការទីផ្សារផលិតផលទៀបនៅក្នុងតំបន់។<br>-បង្កើតទំនាក់ទំនងជាមួយអ្នកប្រមូលទិញផ្ទាល់÷ ធានាបាននូវទីផ្សារសម្រាប់ផលិតផលក្នុង ភូមិ ឃុំ ស្រុក ខេត្ត និងរាជធានី ឱ្យបានទូលំទូលាយ។<br>-ពិពិធកម្មដំណាំ÷កុំពឹងផ្អែកតែដំណាំទៀបតែមួយមុខ ត្រូវដាំដំណាំរួមផ្សំផ្សេងទៀត ដើម្បីកាត់បន្ថយការលើសផលិតលើទីផ្សារ និងគ្មានទីផ្សារលក់ចេញ។<br>-បង្កើតបណ្តុំ ឬសហគមន៍កសិករ÷ រួមគ្នាដើម្បីទទួលបានអំណាចក្នុងការចរចារតម្លៃធាតុចូល និងកាត់បន្ថយថ្លៃដើមដឹកជញ្ជូន។<br>-កែច្នៃផលិតផល បង្កើតម៉ាកយីហោ និងការវេចខ្ចប់ទាក់ទាញ÷កែច្នៃផ្លែទៀបទុំជាទឹកផ្លែឈើកំប៉ុងដើម្បីបង្កើនតម្លៃបន្ថែម<br>-ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយផលិតផលតាមបណ្តាញសង្គមឬវេទិកាអនឡាញដើម្បីពង្រីកទីផ្សារ។ |
| **ហានិភ័យហិរញ្ញវត្ថុ** | **-ថ្លៃចាប់ដើមដំបូងខ្ពស់÷** ការដាំដុះដំបូង ការទិញពូជ ការដំឡើងប្រព័ន្ធធារាសាស្ត្រអាចទាមទារទុនវិនិយោគដំបូងច្រើន។<br>**-ថ្លៃដើមដំណើរការ÷** ថ្លៃដើមបន្តបន្ទាប់រួមមាន ថ្លៃជី ថ្នាំកសិកម្ម ថ្លៃទឹក ថ្លៃពលកម្ម និងថ្លៃថែទាំ។<br>**-ប្រភពហិរញ្ញវត្ថុ÷** កសិករខ្នាតតូចអាចមានការលំបាកក្នុងការទទួលបានប្រាក់កម្ចីពីធនាគារ ឬស្ថាប័ន | -គ្រប់គ្រងចំណូលចំណាយឱ្យបានល្អ÷ កត់ត្រារាល់ចំណូល និងចំណាយ ដើម្បីដឹងពីស្ថានភាពហិរញ្ញវត្ថុពិតប្រាកដ<br>-រៀបចំផែនការអាជីវកម្មលម្អិត÷ វាយតម្លៃថ្លៃដើមប្រាក់ចំណូលដែលរំពឹងទុក និងហានិភ័យ<br>-ស្វែងរកប្រភពទុនពីគ្រឹះស្ថានហិរញ្ញវត្ថុ ឬកម្មវិធីជំនួយរបស់រដ្ឋាភិបាលសម្រាប់វិស័យកសិកម្មដែលមានអត្រាការប្រាក់អនុគ្រោះ។<br>-ប្រើប្រាស់បច្ចេកទេសកាត់បន្ថយថ្លៃដើម÷ ដូចជាការប្រើប្រាស់ជីធម្មជាតិផលិតដោយខ្លួនឯង ឬប្រព័ន្ធធារាសាស្ត្រសន្សំសំចៃទឹក ការប្រើប្រាស់ |

| | | |
|---|---|---|
| | ហិរញ្ញវត្ថុដោយសារតែកង្វះវត្ថុបញ្ចាំ ឬឯកសារត្រឹមត្រូវ។<br>**-ផែនការអាជីវកម្ម÷** កង្វះផែនការអាជីវកម្មច្បាស់លាស់ និងការគ្រប់គ្រងចំណូលចំណាយមិនបានល្អ អាចនាំឱ្យមានបញ្ហាហិរញ្ញវត្ថុ។ | ប្រព័ន្ធពន្លឺព្រះអាទិត្យ និងសហការទិញជីថ្នាំជាបណ្តុំដើម្បីបានតម្លៃទាបជាងការដោយឡែក។<br>-បង្កើតមូលនិធិបម្រុង÷ សន្សំប្រាក់មួយចំណែកសម្រាប់ទប់ទល់នឹងហានិភ័យដែលកើតឡើងដោយចៃដន្យ<br>-ស្វែងយល់ពីកម្មវិធីទិញធានារ៉ាប់រងដំណាំ (ប្រសិនបើមាន)ដើម្បីកាត់បន្ថយហានិភ័យនៃការខាតបង់ធំ។ |

## ៧-សេចក្តីសន្និដ្ឋាន

ដំណាំទៀបស្វិតអាចផ្តល់ផលជាបណ្តើរត្រឹមអាយុជាមធ្យមពីឆ្នាំទី២ឡើងទៅ។ ដំណាំទៀបអាចផ្តល់ទិន្នផលផ្លែជាមធ្យម **៣,០០០ - ១៤,០០០** គ.ក្រ/ហិកតា/ឆ្នាំ ពីឆ្នាំទី២-៦ និងអាចបន្តប្រមូលផលរហូតដល់អាយុ ២០ ឆ្នាំ ឬលើស តែទាមទារការថែទាំដោយយកចិត្តទុកដាក់។ ផ្លែទៀបស្វិតមានទីផ្សារក្នុងស្រុកល្អ ដោយសារទំហំនៃការដាំដុះមិនទាន់ធំធេងនៅឡើយ។ ចំណែកតម្លៃទីផ្សារលក់ដុំជាមធ្យម **៥,០០០** រៀល/គ.ក្រ និងមានថ្លៃដើមផលិតជាមធ្យម **៣,២២៨** រៀល/គីឡូក្រាម។ កសិករអាចទទួលផលចំណេញខ្ពស់ពី **៧,៣១២,០០០ - ៣៤,៥៧០,០០០** រៀល/ហិកតា (ពីឆ្នាំទី ៤-៦) បើទទួលទិន្នផលដូចតារាងខាងលើចន្លោះពី៨-១៤ តោន/ហិកតា។ ចំពោះនិន្នាការតម្លៃលក់រាយផ្លែទៀបស្វិត ទូទៅអាចប្រែប្រួលពី **៨,០០០** រៀល ទៅ **១០,០០០** រៀល/គីឡូក្រាម អាស្រ័យលើបរិមាណនៃការផ្គត់ផ្គង់ និងគុណភាពផ្លែទៀបនៅលើទីផ្សារ។

## ៨-ប្រភពសិក្សា-ឯកសារ


១- សិក្សាលើការអនុវត្តជាក់ស្តែងរបស់កសិករដាំដុះដំណាំទៀបស្វិតនៅ ភូមិទ្រា ខេត្តត្បូងឃ្មុំ

២- សិក្សាលើការអនុវត្តជាក់ស្តែងរបស់កសិករដាំដុះដំណាំទៀបស្វិត ស្រុកសំឡូត ខេត្តបាត់ដំបង

៣- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (២០១៩); អគ្គនាយកដ្ឋានសកិកម្ម; បច្ចេកទេសដាំដំណាំទៀប

៤- Queensland Government.(1998). Before you start: Overview of the Custard Apple industries, Australia.

៥-Kalpana Choudhary and Nirmal Kumar Meena. (2020). *Benefits of pruning custard apples*. Department of Fruit Science, College of Horticulture and Forestry, Jhalawar, AU, Kota (Rajasthan). Indian Horticulture

៦-Haral, Y.R. and Pawar, B.R. (2013). Economics of custard apple production in Maharashtra.*Internat. Res. J. agric. Eco. & Stat.,* **4** (2)

៧-National Institute of Food Technology, Entrepreneurship and Management (NIFTEM).(n. d); *DETAILED PROJECT REPORT FOR PROCESSING OF CUSTARD APPLE RTS BEVERAGES*